# សេចក្តីថ្លែងការណ៍រួម

## សង្គមស៊ីវិលសំដែងការខកចិត្តចំពោះការប៉ុនប៉ងព្យួរអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រគណបក្សជំទាស់

*ភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៩*

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិកម្ពុជា (CHRAC) ដែលជាសម្ព័ន្ធ នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានសមាជិកចំនួន២១ និង គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) សូមសំដែងនូវការខកចិត្តជាខ្លាំងចំពោះការគ្រោងព្យួរអភ័យឯកសិទ្ធិតំណាងរាស្ត្រគណបក្សជំទាស់លោក **សម រង្ស៊ី** ដោយរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសប្តាហ៍ខាងមុខនេះ ។

គណៈកម្មាធិការប្រព្រឹត្តិកម្ម និងគណៈកម្មាធិការខុមហ្វ្រែល យល់ឃើញ ប្រសិនបើមានការសំរេចដោយរដ្ឋសភាកម្ពុជា ដើម្បីធ្វើការព្យួរអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្ររូបនេះពិតមែន នោះ គឺជា ការបន្ថយ និងរំលោភទៅលើសិទ្ធិអំណាចរបស់គណបក្សជំទាស់ និងសេរីភាពបញ្ចេញមតិ ដើម្បីការពារផលប្រយោជន៍របស់ប្រទេសជាតិ សារជាថ្មីទៀត បន្ទាប់ពីត្រូវបានរដ្ឋសភាសំរេចដកអភ័យឯកសិទ្ធិរបស់លោក និងសមាជិកសភាពីររូបទៀត គឺលោក ហូរ វ៉ាន់ និងលោកស្រី មួរ សុខហួរ ជាបន្តបន្ទាប់ នាពេលកន្លងមកនោះ ។

ទោះបីជាការលើកអភ័យឯកសិទ្ធិសមាជិកសភាអាចប្រព្រឹត្តទៅ ក្នុងគោលបំណងអនុញ្ញាតឱ្យតុលាការខេត្តស្វាយរៀងចាត់ការទៅលើបណ្តឹងអំពី "បទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និង បទញុះញង់ឱ្យមានការរើសអើងពូជសាសន៍" ដោយអាជ្ញាធរខេត្តស្វាយរៀងប្រឆាំងនឹងលោកសម រង្ស៊ី ក៏ដោយ សម្ព័ន្ធអង្គការសង្គមស៊ីវិលយល់ឃើញថា ទង្វើបែបនេះមិនគួរកើតឡើងសារជាថ្មីម្តងហើយ ម្តងទៀត ប្រឆាំងតែទៅលើសមាជិកសភាគណបក្សជំទាស់នោះដែរ ។ ម្យ៉ាងទៀត ការសំរេចបែបនេះ ក៏នឹងអាចធ្វើឱ្យបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភា នៃគណបក្សជំទាស់ កាន់តែត្រូវបានសាធារណៈមតិមើលឃើញថា ចុះខ្សោយ និងរងនូវការជ្រៀតជ្រែកដោយសំពាធនយោបាយខ្លាំងពីសំណាក់គណបក្សកាន់អំណាច ពីព្រោះថា អ្នកតំណាងរាស្ត្រត្រូវមានតួនាទី និងបំពេញកិច្ចការនានា ដើម្បីការពារផលប្រយោជន៍របស់ប្រទេសជាតិ ក៏ដូចជា ជួយការពារបូរណភាពទឹកដី និងប្រជាពលរដ្ឋកម្ពុជាឱ្យបានពេញលេញផងដែរ ។

ដូចនេះ សម្ព័ន្ធអង្គការសង្គមស៊ីវិលទាំងពីរ សូមធ្វើការអំពាវនាវដល់សមាជិក សមាជិកា នៃរដ្ឋសភា ជាពិសេសសមាជិកសភាគណបក្សកាន់អំណាច មេត្តាពិចារណាចំពោះការសំរេចព្យួរអភ័យឯកសិទ្ធិសមាជិកសភា សម រង្ស៊ី នៅក្នុងកិច្ចប្រជុំសភាពេញអង្គនៅពេលមុខនេះ ។ ម្យ៉ាងទៀត ទន្ទឹមនឹងនេះដែរ សម្ព័ន្ធអង្គការសង្គមស៊ីវិលខាងលើ ក៏សូមទទូចដល់តុលាការខេត្តស្វាយរៀង ឱ្យបំពេញកិច្ចប្រកបដោយឯករាជ្យ និងមិនលំអៀង ចំពោះករណីនេះ ។

***<u>សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:</u>***

| | | |
|---|---|---|
| លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួល CHRAC និងជានាយក KID | លេខទូរស័ព្ទ: ០១២ ៨៦៥ ៩១០ |
| លោក **នី ចរិយា** | ប្រធានផ្នែកស៊ើបអង្កេត ADHOC | លេខទូរស័ព្ទ: ០១១ ២៧៤ ៩៥៩ |
| លោក **គីម ឈន** | មន្ត្រីជាន់ខ្ពស់កម្មវិធី COMFREL | លេខទូរស័ព្ទ: ០១២ ៩៤២ ០១៩ |
| លោក **គង់ ពិសី** | ប្រធានក្រុមបច្ចេកទេសមេធាវី CDP | លេខទូរស័ព្ទ: ០១២ ៩៤៥ ៧២៥ |